# រឿង សំណាល់ ៥ យ៉ាង



# រឿង សំណល់ ៥ យ៉ាង

និពន្ធដោយ អ្នកស្រី ជិន យ៉ាហាន
គូររូបដោយ លោក សារិទ្ធ ចំរើន

រក្សាសិទ្ធិដោយ អង្គការសន្តិស្មគ្រចិត្ត(SVA)

បោះពុម្ពឆ្នាំ២០១២

# រឿង សំណល់ ៥ យ៉ាង



មានចាបញីឈ្មោលមួយគូដែលទើបនឹងពេញវ័យ បានលាមេបា ទៅរកកន្លែងរស់នៅថ្មី និងចិញ្ចឹមជីវិតដោយខ្លួនឯង ។





ហើរចេញបានឆ្ងាយបន្តិច ចាបញីក៏សម្លឹងមើលមកក្រោមឃើញកុមារតូចម្នាក់ស្ពាយថង់ធំមួយ កំពុងដើរឈ្វេកៗ មិនដឹងថារកអ្វី ។ ចាបញីក៏បបួលចាបឈ្មោលចុះរកចំណីនៅក្បែរនោះ ។





ពេលចុះដល់ដី   ចាបឈ្មោលក៏និយាយទៅកាន់កុមារតូចថា
"ជម្រាបសួរបង!  តើបងកំពុងធ្វើអ្វី?តើប្អូនអាចជួយធ្វើការបងបានឬទេ?"
"អរគុណប្អូន!  ប្អូនអាចជួយរើសវត្ថុសំណល់ទាំងនេះឱ្យបងបាន"
(កុមារតូចឆ្លើយ) ។







កុមារតូចនោះប្រាប់ចាបទាំងពីរថា "ប្អូនដឹងទេ! វត្ថុសំណល់ទាំងនេះគេអាចយកទៅកែច្នៃជាវត្ថុថ្មីផ្សេងៗទៀតបាន ប៉ុន្តែយើងត្រូវរើស និងដាក់វាទៅតាមប្រភេទ" ។



នៅពេលប្អូនរើសបានថង់ប្លាស្ទីក ឬវត្ថុបាក់បែក មានជ័រ ឬកៅស៊ូ ជាដើម ចូរប្អូនយកទៅដាក់នៅធុងទីមួយ ។



បើវាជាអំបែងកែវ ឬដប ចូរប្អូនត្រូវយកទៅដាក់នៅធុងទីពីរ ។



តែបើវាជាសំណល់ធ្វើពីដែក ឬលោហធាតុ
ចូរប្អូនយកទៅដាក់ក្នុងធុងទីបី ។



ប្រសិនបើ ប្អូនរើសបានក្រដាស ប្អូនត្រូវយកទៅដាក់ក្នុងធុងទីបួន។



ដោយឡែក បើវាជាសំណល់ផ្ទះបាយ ចូរប្អូនយកទៅដាក់ក្នុងធុងទីប្រាំ ។ ឯរបស់ណាធ្ងន់ ប្អូនស្រែកប្រាប់បង គឺទុកឱ្យបងរើស ។



ចាបទាំងពីរស្តាប់បានហើយ ក៏ចាប់ផ្តើមធ្វើការ ។ ចាបញីលោតផ្លោតៗ ពាំសំបកប៊ិកយកទៅដាក់ក្នុងធុងទីមួយ ។

ចាបឈ្មោលលោតផ្លោតៗពាំអំបែងកែវយកទៅដាក់ក្នុងធុងទីពីរ ។



ចាបទាំងពីរហើរចុះឡើងៗ ជាច្រើនត្រឡប់ ជញ្ជូនវត្ថុសំណល់បណ្ដើរ និង ឆ្លៀតរកមើលគ្រាប់ស្រូវ គ្រាប់អង្ករ គ្រាប់បាយ ចឹកស៊ីបណ្ដើរៗ ។



ទាំងអស់គ្នាធ្វើការរៀងៗ ខ្លួន ។ ចាបញីប្រទះឃើញកៅស៊ូកង ក៏យកទៅដាក់ក្នុងធុងទីមួយ ។ ឯចាបឈ្មោលឃើញសំបកកំប៉ុងទឹកក្រូច ក៏យកទៅដាក់ក្នុងធុងទីបី ។



នៅពេលពួកគេបានរើសសំណល់មានប្រយោជន៍ជាច្រើនហើយ ចាបឈ្មោល ក៏ផុសគំនិតឆ្ងល់នឹងបញ្ហាវត្ថុសំណល់។ វាសម្លឹងទៅកុមារតូច រួចសួរថា "បងអើយ! បើយើងមិនរើសវត្ថុសំណល់ទាំងនេះទេ តើវានឹងទៅជាយ៉ាងណា?" ។




១
៣
ដបប្លាស្ទិក
ដែកលោហធាតុ

កុមារតូចបានឮហើយ ក៏ប្រាប់ថា "បើយើងមិនរើសវត្ថុសំណល់ទាំងនេះទេ វាអាចក្លាយទៅជាភ្នំសំរាមដែលមានសំណល់គ្រប់ប្រភេទនៅឡូកឡំជាមួយគ្នា ។ ឯសំណល់ខ្លះមិនរលួយ កប់ក្នុងដីធ្វើឱ្យខូចដី ដែលរុក្ខជាតិមិនអាចដុះបាន" ។



ចាបទាំងពីរបើកភ្នែកធំៗ ។ កុមារតូចក៏និយាយបន្ត "មិនតែប៉ុណ្ណោះ វាក៏ធ្វើឱ្យសត្វទាំងឡាយដែលរស់នៅតាមរន្ធក្នុងដីរងជាតិពុលដែរ ។ម្យ៉ាងទៀត បើជាតិពុលនេះហូរចូលទៅក្នុងទឹកស្រះ ត្រពាំង បឹងបួ ស្ទឹងណាមួយ វានឹងធ្វើឱ្យសត្វដែលរស់នៅក្នុងទឹក និងអ្នកប្រើប្រាស់ទឹកនោះពុលទៀតផង" ។



ចាបទាំងពីរនៅតែឆ្ងល់ ។ "ដើម្បីកុំឱ្យវត្ថុសំណល់នេះបញ្ចេញជាតិពុល ចូលទៅក្នុងដី ឬទឹក ម្ដេចយើងមិនដុតវាចោលទៅ?"(ចាបឈ្មោលសួរ) ។




១
២
ជ័រប្លាស្ទិក
អំបែងដបកែវ



កុមារតូចតបថា "អូ! ដុតបែបនេះក៏មិនបានដែរ ព្រោះសំណាល់ខ្លះនឹងបញ្ចេញផ្សែងពុល ។ ផ្សែងពុលនោះនឹងប៉ះពាល់ដល់សុខភាពយើងអាចនឹងបង្កជម្ងឺជាមិនខាន" ។ ឮដូច្នោះហើយ ចាបក៏ក្រាបចុះដោយក្ដីបារម្ភ ។





ឃើញចាបព្រួយបារម្ភដូច្នេះ កុមារតូចក៏អះអាងថា "ប៉ុន្តែ យើងអាចបញ្ចៀសគ្រោះថ្នាក់បាន ដោយគ្រាន់តែរើសវត្ថុសំណល់ទាំងនោះ យកទៅលក់ឱ្យរោងចក្រកែច្នៃធ្វើជារបស់ប្រើប្រាស់ផ្សេងៗជាថ្មីម្តងទៀត" ។





ចាបទាំងពីរក៏និយាយដោយក្តីរីករាយថា “នេះជាមធ្យោបាយល្អណាស់បង ។ ពួកយើងគួរតែប្រាប់អ្នកឯទៀត កុំឱ្យបោះវត្ថុសំណល់ចោលឥតសណ្តាប់ធ្នាប់ ត្រូវទុកដាក់ឱ្យបានត្រឹមត្រូវ” ។

ពួកគេទាំងបីសប្បាយចិត្តយ៉ាងខ្លាំង ព្រោះគេបានទុកដាក់សំណល់តាមប្រភេទរួចហើយ ។

...ចប់...



*Move forward, hand in hand*

Shanti Volunteer Association

*Stand with people in need around the world*